00337342

E65/2

នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| បណ្តឹងឧទ្ធរណ៍លេខ: | ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ |
| ថ្ងៃដាក់: | ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៩ |
| ភាគីអ្នកដាក់: | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារដែលស្នើឡើង: | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / JUNE / 2009
ម៉ោង (Time/Heure) : 17:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fny

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា
## ទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់
## មួយចំនួន សុំឲ្យធ្វើការបង្ហាញរបាយការណ៍របស់ UN-OIOS

---

**អ្នកដាក់ឯកសារ:**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក សេង ប៊ុនឃាង
លោក Anees AHMED

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក Karim A. A. KHAN
កញ្ញា ទី ស្រីនណា
លោក Alain WERNER
លោកស្រី Brianne McGONIGLE

**មេធាវីជនជាប់ចោទ**

លោក ការ សាវុត្ថ
លោក François ROUX

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 04 / JUN / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fny

## ១. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញា ដាក់ចម្លើយតបនេះ ("ចម្លើយតប") ទៅនឹងពាក្យសុំ ("ពាក្យសុំ") របស់ដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់មួយចំនួន ដែលស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ជួយសម្រួលឱ្យមានការផ្សព្វផ្សាយនូវ របាយការណ៍របស់ការិយាល័យអង្គការសហប្រជាជាតិផ្នែកសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង ("របាយការណ៍ OIOS") ទាក់ទងនឹងការស្រាវជ្រាវធ្វើឡើងដោយអង្គការនេះ នៅលើការលើកឡើងអំពីអំពើពុករលួយក្នុងផ្នែករដ្ឋបាល នៅក្នុងតុលាការនេះ[1] ។

## ២. អំណះអំណាង
## ក. សេចក្តីសម្រេចគួរតែត្រូវបានពន្យារពេល

២. សហព្រះរាជអាជ្ញា សន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង គួរតែពន្យារពេលលើការសម្រេចរបស់ខ្លួនលើពាក្យសុំនេះ រហូតដល់អង្គបុរេជំនុំជម្រះ បានដោះស្រាយលើបណ្តឹងឧទ្ធរណ៍ជាសារវ័ន្តចំនួនបួន នៅចំពោះមុខខ្លួន ដែលលើកឡើងពីបញ្ហាស្រដៀងគ្នា និងស្វែងរកដំណោះស្រាយស្រដៀងគ្នា ។

៣. បណ្តឹងឧទ្ធរណ៍ បានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយជនត្រូវចោទ នួន ជា[2], អៀង សារី[3], អៀង ធីរិទ្ធ[4] និង ខៀវ សំផន[5] ("បណ្តឹងឧទ្ធរណ៍អំពីអំពើពុករលួយ") ដែលស្វែងរក

---

[1] ក្រុម ១ - ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ជួយសម្រួលឱ្យមានការផ្សព្វផ្សាយដល់ភាគីនូវរបាយការណ៍របស់ UN-OIOS ។

[2] *ករណីរបស់ នួន ជា,* បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទី ១១ ស្នើសុំបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ២១), D158/5/1/1 [*ចាប់ពីនេះតទៅហៅថា* បណ្តឹងឧទ្ធរណ៍របស់ នួន ជា] ។

[3] *ករណីរបស់ អៀង សារី,* បណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបំពេញកិច្ចស៊ើបសួរអំពីការចោទប្រកាន់ជាហូរហែរអំពីអំពើពុករលួយ និងសំណើសុំចាត់ការសវនាការដេញដោលផ្ទាល់មាត់ឱ្យឆាប់រហ័ស, ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ២០), D158/5/3/1 [*ចាប់ពីនេះតទៅហៅថា* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី] ។

ដាច់ដោយឡែកពីគ្នានូវការកែប្រែដីកាសម្រេចជារួមមួយ របស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងការលើកឡើងអំពីអំពើពុករលួយក្នុងផ្នែករដ្ឋបាលក្នុងតុលាការនេះ[6] ។ សំណើសុំនេះ ដែលបានដាក់ដោយ នួន ជា ("សំណើសុំបំពេញកិច្ចស៊ើបសួរ")[7] បានស្នើឱ្យសហចៅក្រមស៊ើបអង្កេត ទទួល និងផ្សព្វផ្សាយ នូវព័ត៌មានជាក់លាក់មួយចំនួនទាក់ទងនឹងការលើកឡើងអំពីអំពើពុករលួយ រួមទាំងរបាយការណ៍របស់ OIOS ផង[8]។

៤. បណ្តឹងឧទ្ធរណ៍អំពីអំពើពុករលួយ និងពាក្យសុំ ព្រួយបារម្ភជាពិសេសទៅលើបញ្ហាដូចគ្នា - ផលប៉ះពាល់ដែលអាចកើតមានឡើងទៅនឹង ការលើកឡើងអំពីអំពើពុករលួយ នៅក្នុងផ្នែករដ្ឋបាល ទៅលើសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌របស់ចុងចោទ នៅចំពោះមុខតុលាការនេះ - និងបានលើកនូវអង្គហេតុរួម ឬស្រដៀងគ្នា និងសំណួរនានាលើបញ្ហាច្បាប់។ អាស្រ័យហេតុនេះ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនៅលើបណ្តឹងឧទ្ធរណ៍ទាំងនេះ នឹងពាក់ព័ន្ធផ្ទាល់ទៅលើបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យសុំ នៅចំពោះមុខតុលាការនេះ ។

៥. អង្គជំនុំជម្រះសាលាដំបូង និងអង្គបុរេជំនុំជម្រះ មានភាពស្មើគ្នានៅក្នុងឋានានុក្រមតុលាការនៃអង្គជំនុំជម្រះនេះ ។ អង្គជំនុំជម្រះ ដែលមានភាពស្មើគ្នាទាំងពីរក្នុងតុលាការតែមួយដូចគ្នានេះ ជាធម្មតា មិនគួរស្តាប់សវនាការលើបញ្ហាតែមួយបណ្តាក់គ្នាឥតដាច់នោះទេ ។ បណ្តឹងឧទ្ធរណ៍អំពីអំពើពុករលួយ ដែលបានដាក់នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩ ត្រូវបានដាក់ជា

---

[4] *ករណីរបស់ អៀង ធីរិទ្ធ,* បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៩ របស់សហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ១៩), D158/5/4/1 ។

[5] *ករណីរបស់ ខៀវ សំផន,* បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៩ របស់សហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩, *[Appel de la défense de M. Khieu Samphan contre l'ordonnance des co-juges d'instruction sur demande d'acte d'instruction en date du 3 avril 2009, ចុះថ្ងៃទី០៤ ខែ មេសា ឆ្នាំ ២០០៩]* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ២២), D158/5/2/1 ។

[6] *ករណីរបស់ នួន ជា,* ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៩, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, D158/5 ។

[7] *ករណីរបស់ នួន ជា,* សំណើលើកទី ១១ ស្នើសុំបើកកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, D158 [*ចាប់ពីនេះតទៅហៅថា* សំណើសុំបើកកិច្ចស៊ើបសួរ] ។

[8] ដូចកំណត់សំគាល់ជើងទំព័រខាងលើ, កថាខ័ណ្ឌទី ២២ ។

លើកដំបូង និងត្រូវបានគេរំពឹងថា នឹងត្រូវបានសម្រេចរួមគ្នា និងយ៉ាងឆាប់រហ័ស ។ គ្មានភាពចាំបាច់ជាបន្ទាន់ណាមួយដែលអង្គជំនុំជម្រះសាលាដំបូង ត្រូវសម្រេចនៅលើពាក្យសុំនេះ នៅមុនពេលមានសេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍អំពីអំពើពុករលួយទាំងនោះទេ ។ ការពន្យារពេលលើការសម្រេចរបស់ខ្លួនលើពាក្យសុំនេះដោយអង្គជំនុំជម្រះសាលាដំបូង រហូតដល់មានសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍អំពីអំពើពុករលួយ បំរើដល់ធនធានរបស់តុលាការនេះផង និងធានាបានលើវិន័យរបស់តុលាការនេះផង ។ អាស្រ័យហេតុដូច្នេះ គ្មានអ្វីត្រូវខាតបង់ទេ ហើយនឹងទទួលបានផលចំណេញយ៉ាងច្រើនពីការពន្យារពេលនេះ ។

## ខ. សំណើសុំរបាយការណ៍ OIOS គួរតែត្រូវបានបដិសេធចោល

៦. សេចក្តីសន្និដ្ឋានជាបឋមរបស់សហព្រះរាជអាជ្ញា ដូចបានជំរាបជូនខាងលើ គឺថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង គួរតែត្រូវបានពន្យារពេល រហូតដល់មានដំណោះស្រាយលើបណ្តឹងឧទ្ធរណ៍អំពីអំពើពុករលួយ ។ ប៉ុន្តែ បើសិនអង្គជំនុំជម្រះសាលាដំបូងជ្រើសរើសធ្វើការសម្រេចលើពាក្យសុំនេះ មុនពេលមានការកំណត់សម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍អំពីអំពើពុករលួយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ពាក្យសុំនេះ គួរតែត្រូវបានច្រានចោល ។

៧. សហព្រះរាជអាជ្ញា តម្រូវឱ្យធ្វើចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍អំពីអំពើពុករលួយ ត្រឹមថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៩[9] ។ ដោយស្របគ្នានឹងគោលជំហររបស់សហព្រះរាជអាជ្ញា នៅក្នុងចម្លើយតបរួមរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍អំពីអំពើពុករលួយ សហព្រះរាជអាជ្ញា សន្និដ្ឋានថា ពាក្យសុំនៅចំពោះមុខអង្គជំនុំជម្រះនេះ គួរតែបានបដិសេធចោល ដោយសារមូលហេតុដូចតទៅ ។

### *សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ គឺជាសិទ្ធិជាមូលដ្ឋាន*

---

[9] សេចក្តីសម្រេចលើពាក្យសុំរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យបន្ថែមចំនួនទំព័រ និងពន្យារពេលវេលាកំណត់ ដើម្បីដាក់ចម្លើយតបរួមរបស់ខ្លួន ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីអំពើពុករលួយ, ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អបជ ២០) D158/5/4/8 ។

*និងដែលគ្រប់អង្គភាពទាំងអស់របស់តុលាការនេះត្រូវតែគោរពតាមដោយខ្ជាប់ខ្ជួន*

៨. ក្នុងខណៈពេលបង្កើតតុលាការពិសេសដែលធ្វើឱ្យទៅជាលក្ខណៈអន្តរជាតិនេះ ដែលមានអាណត្តិខុសគេតែមួយគត់ អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា បានព្រមព្រៀងគ្នា ("កិច្ចព្រមព្រៀង") ថា តុលាការនេះ ត្រូវអនុវត្តនូវយុត្តាធិការរបស់ខ្លួន ស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ មានភាពត្រឹមត្រូវតាមនីតិវិធីនៃច្បាប់ ដូចដែលមាន ចែងនៅក្នុង មាត្រា ១៤ និង១៥ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")[10] ។

៩. នៅក្នុងមាត្រា១៤ នៃកតិកាសញ្ញា ICCPR មានចែងអំពីបទដ្ឋានអប្បបរិមានៃ "សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌" របស់ចុងចោទនៅចំពោះមុខតុលាការនេះ[11] ។ ពាក្យថា "សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌" គឺមិនចាំបាច់យោងតែទៅលើសិទ្ធិផ្សេងៗ ដែលចុងចោទត្រូវបានទទួលនៅក្នុងពេលសវនាការប៉ុណ្ណោះទេ ជាក់ស្តែង គឺមានសិទ្ធិភាគច្រើនក្នុងចំណោម "សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌"ទាំងនេះ ចាំបាច់ត្រូវបានយកមកអនុវត្តជាក់ស្តែងនៅក្នុងដំណាក់កាលនៃការស៊ើបសួរ និងក្នុងដំណាក់កាលមុន សវនាការនៃដំណើរការនីតិវិធីរបស់តុលាការនេះ[12]។ ស្របតាមនេះ ដោយស្រង់យកមាត្រា៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើតតុលាការនេះ ("ច្បាប់ អ.វ.ត.ក ") អង្គបុរេជំនុំជម្រះបានកត់សំគាល់ថា ចុងចោទទាំងឡាយនៅចំពោះមុខតុលាការនេះ បានទទួលនូវសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ "ចាប់តាំងពីពេលចាប់ផ្តើមកិច្ចស៊ើបសួរមកម្ល៉េះ"[13] ។ នៅក្នុងវិធីស្រដៀងគ្នានេះ តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") បានសម្រេចថា ការធានារ៉ាប់រងឱ្យមានការជំនុំជម្រះក្តីដោយត្រឹមត្រូវ

---

[10] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ មិថុនា ២០០៣, មាត្រា ១២.២ [*ដែលតទៅទៀតនៅក្នុងនេះហៅថា* កិច្ចព្រមព្រៀង]។

[11] ច្បាប់ អ.វ.ត.ក មាត្រា៣៥ថ្មី។

[12] ឧទាហរណ៍ដូចជា សិទ្ធិក្នុងការមានមេធាវីការពារក្តី សិទ្ធិមិនផ្តល់សក្ខីកម្ម សិទ្ធិត្រូវបានសន្មត់ថាមិនទាន់មានទោសនៅឡើយ។

[13]ករណីរឿងរបស់ នួន ជា, ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការតែងតាំងអ្នកជំនាញមួយរូប សំណុំរឿងលេខ 00២/១៩-0៩-២០0៧- អ.វ.ត.ក/ក.ស.ច.ស, ឯកសារលេខ D54/5/6, កថាខណ្ឌ ២៥ ។

យុត្តិធម៌ គឺមិនកំរិតត្រឹមតែនៅក្នុងពេលជំនុំជម្រះក្តីតែប៉ុណ្ណោះទេ ក៏ប៉ុន្តែលាតសន្ធឹងទៅដល់ពេលដំណើរការរឿងក្តីតាំងពីមុនពេលជំនុំជម្រះក្តីផងដែរ ជាក់ស្តែងគឺលាតសន្ធឹងទៅដល់គ្រប់ទិដ្ឋភាពទាំងអស់ នៃដំណើរការនីតិវិធី[14] ។ ក្នុងលក្ខណៈស្របគ្នាជាមួយនឹងកិច្ចព្រមព្រៀង វិធាន២១.១ នៃវិធានផ្ទៃក្នុង ("វិធាន") ក៏បានចែងធានាផងដែរអំពី "គោលការណ៍ជាសារវន្ត" មួយចំនួនដែលរួមទាំងគោលការណ៍ដែលចែងថា ដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះត្រូវតែ "មានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ"[15] ។

១០. គោលការណ៍ជាសារវន្ត ដែលចែងថា ដំណើរការនីតិវិធីរបស់ អ.វ.ត.ក នេះត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខនេះ ត្រូវតែអនុវត្តដោយស្មើភាពគ្នាចំពោះរាល់អង្គភាពទាំងអស់របស់តុលាការនេះ ។ ពីព្រោះការធានារ៉ាប់រងអំពីសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ដែលលាតសន្ធឹងទៅដល់គ្រប់ទិដ្ឋភាពទាំងអស់នៃដំណើរការនីតិវិធីនោះ សិទ្ធិនេះមានវិសាលភាពគ្របដណ្តប់ទៅលើគ្រប់អង្គភាពទាំងអស់របស់ អ.វ.ត.ក ដើម្បីធានាថា សិទ្ធិជាមូលដ្ឋានទាំងនេះត្រូវបានគោរពតាមយ៉ាងខ្ជាប់ខ្ជួន ។ កាតព្វកិច្ច និង សិទ្ធិអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង និងការិយាល័យសហចៅក្រមស៊ើបអង្កេត នៅក្នុងរឿងនេះ គឺដូចគ្នា ។

*បញ្ហាស្តីពីសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌*
*មិនត្រូវបានលើកឡើងដោយជនជាប់ចោទទេ*

១១. ដូចដែលបានលើកឡើងរួចមកហើយ បញ្ហាផ្សេងៗដែលបានលើកឡើងទាំងនៅក្នុងពាក្យសុំក្តី និងទាំងនៅក្នុងបណ្តឹងឧទ្ធរណ៍ស្តីពីអំពើពុករលួយ ជាសំខាន់បំផុតគឺទាក់ទងនឹងលទ្ធភាពដែល

---

[14] *សភាពការណ៍នៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុងករណីរឿងរបស់ រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo,* សាលដីកាសេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ប្រឆាំងនឹង ដីកាសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងទី១ដែលមានចំណងជើងថា ដីកាសម្រេចស្តីពីផលវិបាកផ្សេងៗនៃការមិនបង្ហាញជូននូវឯកសារដោះបន្ទុកនានា ដែលគ្របដណ្តប់ដោយមាត្រា៥៤.៣.ង នៃកិច្ចព្រមព្រៀង និងពាក្យសុំឲ្យផ្អាកការចោទប្រកាន់ទៅលើជនជាប់ចោទ ដោយរួមបញ្ចូលគ្នាជាមួយនឹងបញ្ហាជាក់លាក់ដទៃៗទៀតដែលលើកឡើងនៅឯអង្គសន្និសីទស្តីពីឋានៈ កាលពីថ្ងៃទី១០ មិថុនា ២០០៨, សំណុំរឿងលេខ ICC-01/04-01/06 OA 13 ចុះថ្ងៃទី២១តុលា២០០៨ មតិដាច់ដោយឡែករបស់ចៅក្រម Georghios M. Pikis, ត្រង់កថាខណ្ឌទី ៤៤ ។

[15] វិធាន ២១.១.ក នៃវិធានផ្ទៃក្នុង ។

អាចមានផលប៉ះពាល់ ដោយសារការលើកឡើងអំពីអំពើពុករលួយផ្នែករដ្ឋបាល ទៅ ដល់សិទ្ធិរបស់ចុងចោទនានាក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ នៅចំពោះមុខតុលាការនេះ ។ ក៏ប៉ុន្តែ ពាក្យសុំដែលស្ថិតនៅពោះមុខអង្គជំនុំជម្រះសាលាដំបូង ត្រូវបានដាក់ដោយសហមេធាវីការពារក្តីនៃដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ។ ជនជាប់ចោទ ឈ្មោះកាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលជាភាគីមួយនៅក្នុងសំណុំរឿងលេខ ០០២ មិនបានលើកឡើងនូវបញ្ហានេះនៅក្នុងសំណុំរឿងណាមួយនៃសំណុំរឿងទាំងពីរទេ ។ ជាក់ស្តែង សូម្បីតែនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ៤រូប ផ្សេងទៀត នៅចំពោះមុខអង្គបុរេជំនុំជម្រះក្តី ក៏គាត់មិនបានចូលរួមដែរ ។

១២. នៅក្នុងពាក្យសុំមិនបានបង្ហាញឲ្យឃើញពី ឬចោទប្រកាន់ថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីនានាបានទទួលរងនូវភាពអយុត្តិធម៌ណាមួយនោះឡើយ ។ ពាក្យសុំនេះត្រូវបានកម្រិត ត្រឹមតែការផ្តៀតឱកាសយកចំណេញក្នុងការតវ៉ាទាមទារដែលថា ឌុច ហើយនិង ជនដទៃទៀតដែលមិនមានការបញ្ជាក់ច្បាស់ "អាចនឹង" ធ្វើនៅក្នុងពេលអនាគត ។ ដូចដែលបាន បង្ហាញជូនខាងក្រោមនេះនៅក្នុងពាក្យសុំ គឺមានការខកខានមិនបានបង្ហាញភស្តុតាងអំពីការជាប់ទាក់ទងគ្នាណាមួយ រវាងការលើកឡើងអំពីអំពើពុករលួយផ្នែករដ្ឋបាល ដែលជាកម្មវត្ថុនៃរបាយការណ៍របស់ការិយាល័យ OIOS និងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ ។

*សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌មិនត្រូវបានរំលោភបំពានទេ*

១៣. ភាគីណាមួយដែលស្នើសុំត្រូវតែបង្ហាញភស្តុតាងនៅក្នុងករណីរឿងរបស់ខ្លួន ។ ពាក្យសុំបានលើកឡើងតវ៉ាថា "មានហានិភ័យដ៏ធំមួយដែលខ្លាចក្រែងថា សាលក្រមនឹងត្រូវបានធ្វើឲ្យខូចដោយសារតែលទ្ធផលដែលបណ្តាលមកពី [ការលើកឡើងអំពីអំពើពុករលួយផ្នែករដ្ឋបាលនេះ]"[16] និងបង្កប់ន័យថា ការលើកឡើងនានាអំពីអំពើពុករលួយអាចនឹងគំរាមកំហែងដល់សិទ្ធិរបស់ជនចាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ នៅចំពោះមុខតុលាការមួយដែលឯករាជ្យនិងមិនលំអៀង[17] ។ ក៏ប៉ុន្តែ នៅក្នុងពាក្យសុំនោះមានការខកខាន

---

[16] ពាក្យសុំ, កំណត់ទី១ *ខាងលើ,* កថាខណ្ឌទី៩ ។

[17] *ដូចខាងលើ* ត្រង់កថាខណ្ឌទី៧ ។

មិនបានពន្យល់អំពីថា តើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌របស់ភាគីណាត្រូវបាន ឬអាចនឹងត្រូវរំលោភបំពានបែបដូចម្តេចខ្លះនោះឡើយ ។ ក្នុងពាក្យសុំនេះ គ្មានអ្វីដែលបង្ហាញថា មានការជាប់ទាក់ទងគ្នារវាងការលើកឡើងអំពីអំពើពុករលួយផ្នែករដ្ឋបាល ហើយនិងការធ្វើសេចក្តីសម្រេចរបស់តុលាការនេះទេ[18] ។

១៤. ដោយគ្មានការជាប់ទាក់ទងគ្នាណាមួយរវាងរបាយការណ៍របស់ការិយាល័យ OIOS ទៅនិងការចោទប្រកាន់អំពីការរំលោភបំពានដ៏មានសក្តានុពល ទៅលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះ ក្តីដោយត្រឹមត្រូវយុត្តិធម៌នោះ វិធានការណ៍ដែលបានស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូង មិនអាចទទួលធ្វើបានទេ[19] ។ ពាក្យសុំគ្រាន់តែប៉ាន់ប្រមាណថា របាយការណ៍របស់ការិយាល័យ OIOS *អាច* នឹងដាក់ឱ្យសាលក្រមនៃការជំនុំជម្រះក្តីប្រឈមមុខទៅនឹងការតវ៉ាទាមទារផ្សេងៗ ដែលថាជនចាប់ចោទ-មិនបានលើកឡើងអំពីរឿងនេះដោយខ្លួនឯង-*អាច* នឹងលើកឡើងនៅក្នុងពេលអនាគតដោយលើកឡើងអំពីអំពើពុករលួយផ្នែករដ្ឋបាល នៅក្នុងតុលាការនេះ ដែល បណ្តាលឱ្យការជំនុំជម្រះក្តីនេះ គ្មានភាពត្រឹមត្រូវយុត្តិធម៌បង្កើតបានជាការរំលោភបំពានទៅលើដំណើរការរឿងក្តីមួយ ដែលនឹងត្រូវចេញដីកាឱ្យផ្អាកដំណើរនៃនីតិវិធីជា

[18] សេចក្តីសម្រេចជាសាធារណៈលើបណ្តឹងសុំដីតចិត្តជាបន្ទាន់ចំពោះលោកចៅក្រម ន័យ ថុល ក្នុងពេលរង់ចាំបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននៅក្នុងករណីរបស់ នួន ជា ចុះថ្ងៃទី៤ កុម្ភៈ ២០០៨ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ ០១), កថាខណ្ឌទី១៩ និងទី២០។ សហរដ្ឋអាមេរិក ករណីរឿងក្តីរបស់ *Shaw ទល់នឹង Commonwealth of Pennsylvania* (580A.2d 1379) (តុលាការកំពូលនៃរដ្ឋ Pennsylvania ឆ្នាំ១៩៩០) និងករណីរឿងក្តីរបស់ *ប្រជាជន ទល់នឹង Titone* (600 N.E.2d 1160, 1166 (Ill.1992) បង្កើតឡើងនូវលក្ខខណ្ឌតម្រូវចំនួន២ ដែលត្រូវតែរកឱ្យឃើញនៅមុនពេលដែលចៅក្រមមួយរូបនឹងត្រូវបានគេបកស្រាយថា មានភាពលំអៀង ឬមួយក៏គ្មានភាពឯករាជ្យ/ភាពមិនលំអៀងដោយមានភស្តុតាងបញ្ជាក់ នោះគឺបានន័យថា: (១) ការជាប់ទាក់ទងគ្នារវាងសកម្មភាពផ្សេងៗដែលមានបញ្ហា [គឺអំពីបញ្ហាពុករលួយ] និងការប្រព្រឹត្តិរបស់ចៅក្រមនៅក្នុងសវនាការ ។ និង (២) ភាពលំអៀងដែលជាលទ្ធផលចេញមកពីការប្រព្រឹត្តិក្រៅប្រព័ន្ធតុលាការ : *Titone* នៅត្រង់ ១១៦៦ ។

[19] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដាបានសំរេចថា បន្ទុកក្នុងការបង្ហាញភស្តុតាងឱ្យឃើញពីតុលាការនេះ គ្មានភាពមិនលំអៀងដោយ "ភស្តុតាងដែលគ្រប់គ្រាន់ និងដែលអាចឱ្យជឿទុកចិត្តបាន" គឺស្ថិតនៅលើចុងចោទ និងថាការដែលគ្រាន់តែ "ចោទប្រកាន់ដោយត្រង់ៗ" ថាមានភាពលំអៀង និងថាការចោទប្រកាន់ដោយការជ្រើសរើស គឺជាការមិនគ្រប់គ្រាន់ក្នុងការបំពេញបន្ទុក នោះទេ ។ *ករណីរឿង រដ្ឋអាជ្ញា ទល់នឹង Akayesu,* សាលក្រមនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍ សំណុំរឿងលេខ ICTR-96-4, ចុះថ្ងៃទី១ មិថុនា ២០០១, កថាខណ្ឌទី ៨០ ។

អចិន្ត្រៃយ៍[20] ឬធ្វើឱ្យលេចឡើងបែបណាមួយនូវការតវ៉ាទាមទារអំពីការធ្វើជាអ្នកតំណាងដែលគ្មានប្រសិទ្ធភាព[21] ។

១៥. ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញ ឬមួយរកឃើញថា មានការជាប់ទាក់ទងគ្នារវាងការលើកឡើងអំពីអំពើពុករលួយផ្នែករដ្ឋបាល ហើយនិងការធ្វើសេចក្តីសម្រេចរបស់តុលាការនេះ ឬមួយថា មានជាការរំលោភបំពានទៅលើសិទ្ធិរបស់ជនចាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌នោះ ទើបអង្គជំនុំជម្រះសាលាដំបូងអាចមានសិទ្ធិអំណាច ដើម្បី (១) ដាក់ទណ្ឌកម្មចំពោះការជ្រៀតជ្រែកណាមួយចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ (វិធាន៣៥ នៃវិធានផ្ទៃក្នុង) ឬ (២) ចាត់វិធានការណ៍ដើម្បីដឹតចិត្តចៅក្រមមួយ ឬច្រើនរូបរបស់ខ្លួនដែលមានភាពលំអៀង (វិធាន៣៤ នៃវិធានផ្ទៃក្នុង)[22] ។ អង្គជំនុំជម្រះ នេះមិនទាន់បានទទួលពាក្យសុំណាមួយដែលប្តឹងមកដោយអនុលោមតាមវិធានទាំងនេះទេ ។

១៦. ពាក្យសុំនេះ មិនបានផ្តល់នូវភស្តុតាងអំពីភាពមិនត្រឹមត្រូវចំពោះភាគីណាមួយឡើយ។ មិនមានសំណើអំពីភស្តុតាងដែលត្រូវបានប្រឡាក់ប្រឡូស, ភាពមិនត្រឹមត្រូវនៅក្នុងដំណើរការនីតិវិធី ឬការរំលោភបំពានលើនីតិវិធីនោះទេ។ វាត្រូវបានបើកចំហរ ចំពោះអ្នកដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយនៅពេលណាក៏ដោយ នៅក្នុងអំឡុងពេលនៃការស៊ើបសួរ បើពួកគេបានពិចារណាថា ផ្នែកណាមួយនៃដំណើរការនីតិវិធី ត្រូវចាត់ទុកជាមោឃៈ ដើម្បី ស្វែងរកនូវមោឃៈភាពនៃដំណើរការនីតិវិធី ដែលត្រូវបានប្រឡាក់ប្រឡូសដោយសារ "វិការៈផ្នែកនីតិវិធី" (វិធាន ៧៦) ។ ដូចដែលបានអះអាងនៅក្នុងសំណើរបស់ នួន ជា សុំឱ្យមានកិច្ចស៊ើបសួរ និងបណ្តឹងឧទ្ធរណ៍ស្តីពីខ្លឹមសារនៃអំពើពុករលួយ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ជាការលើកឡើងអំពីអំពើពុករលួយផ្នែករដ្ឋបាល ដែលត្រូវបានលើកឡើងអស់រយៈពេលជាងពីរឆ្នាំ

---

[20] ពាក្យសុំ *ខាងលើ* កំណត់ទី១ កថាខណ្ឌទី២ (សង្កត់ពាក្យដោយអក្សរទ្រេត) ។

[21] *ដូចខាងលើ* ត្រង់កថាខណ្ឌទី៧ (សង្កត់ពាក្យដោយអក្សរទ្រេត) ។

[22] ទោះបីជាមិនមានវចនាបទជាពាក្យសុំដឹតចិត្តចៅក្រមក្តី ក៏ពាក្យសុំមិនបានចង្អុលទៅលើចំណុចណាមួយនៅក្នុងសំណុំរឿងដែលស្នើថាចៅក្រម១រូបឬច្រើនរូបត្រូវសុំបានដឹតចិត្តដែរ ។

មកហើយ។ វាត្រូវបានបើកចំហរចំពោះភាគីនានា ក្នុងការដាក់ពាក្យសុំនៅពេលនោះ[23]។ បន្ថែមលើនេះ ការបង្ហាញនូវ សក្ខីកម្មអំពីការរំលោភសិទ្ធិអ្វីមួយដែល ICCPR បានទទួលស្គាល់ក៏អាចជាមូលហេតុមួយ នៃមោឃៈភាពបានដែរ[24] ។ អ្នកដាក់ពាក្យសុំ មិនបានផ្តល់អំណះអំណាងថាមានវិការៈផ្នែកនីតិវិធីណាមួយ ដែលបណ្តាលឱ្យ មានការរំលោភទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ[25] ឬក៏សូម្បីតែ ដាក់ពាក្យសុំមោឃៈភាពលើសកម្មភាពស៊ើបសួរណាមួយទៅតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុងក៏គ្មានដែរ[26] ។

*អង្គជំនុំជម្រះនេះ មិនមែនជាវេទិកាដ៏សមស្របមួយ*
*សម្រាប់ធ្វើការស៊ើបសួរ លើការលើកឡើងអំពីអំពើពុករលួយទេ*

១៧. ការស៊ើបសួរ (ឬ ការបង្កើតឡើងនូវ "យន្តការស៊ើបសួរ"[27]) អំពីការលលើកឡើងថាមន្ត្រីរដ្ឋបាលផ្នែកជាតិមួយចំនួននៃអង្គជំនុំជម្រះនេះ បានបង់ប្រាក់កាសដើម្បីឱ្យបាន ឬដើម្បីរក្សា នូវមុខដំណែងរបស់ពួកខ្លួន ដែលជាការមួយមិនអាចទទួលយកបាននៅតាមស្ថាប័នណាមួយ ក៏ដោយ ជាពិសេសនៅតាមស្ថាប័នយុត្តិធម៌ គឺត្រូវស្ថិតនៅក្រោម៖ ទី១) យុត្តាធិការលើវិន័យ

[23] ប្រវត្តិអង្គហេតុនៃការលើកឡើងអំពីអំពើពុករលួយ គឺត្រូវបានចាប់ផ្តើមយ៉ាងធំទូលាយនៅក្នុងសំណើសុំឱ្យមានកិច្ចស៊ើបសួរ, កំណត់សម្គាល់ទី៧ *ខាងលើ,* កថាខណ្ឌទី៤-១៤ ។ សូមមើលផងដែរ, បណ្តឹងឧទ្ធរណ៍របស់ នួន ជា, កំណត់សម្គាល់ទី២ *ខាងលើ,* កថាខណ្ឌទី២-៦ ។ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, កំណត់សម្គាល់ទី៣ *ខាងលើ,* កថាខណ្ឌទី២ ។

[24] អង្គបុរេជំនុំជម្រះ យល់ឃើញថា ការបង្ហាញអំពីការរំលោភសិទ្ធិរបស់ជនត្រូវចោទ ដែលត្រូវបានទទួលស្គាល់នៅក្នុង ICCPR អាចបង្កប់ជាកំហុសនីតិវិធី ហើយនិងប៉ះពាល់ដល់ផលប្រយោជន៍របស់ជនត្រូវចោទ ។ នៅក្នុងករណីបែបនេះ កិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការអាចចាត់ទុកថាមោឃៈ ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំ មោឃភាព, ចុះថ្ងៃទី២៦ សីហា ២០០៨, ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អបជ-០៦), D55/I/8, កថាខណ្ឌទី៤០ [*ចាប់ពីនេះតទៅហៅថា* សាលដីកាលើពាក្យសុំមោឃភាពរបស់ នួន ជា] ។

[25] អង្គបុរេជំនុំជម្រះ យល់ឃើញថាដោយមានការពាក់ព័ន្ធទៅនឹងវិធាន ៧៦.២ នៃវិធានផ្ទៃក្នុង សំណើសុំមោឃភាពត្រូវតែមាន៖ ទី១) វត្តមាននៃមោឃភាពនីតិវិធី និងទី២) នៅពេលមានវិការភាពនៃនីតិវិធី កំហុសនីតិវិធីនេះ ដាច់ខាតបង្កើតបានជាការរំលោភសិទ្ធិរបស់ភាគីដែលបានដាក់ពាក្យសុំ ។ បន្ថែមលើនេះ នៅក្នុងវិធានផ្ទៃក្នុងមិនមានបទប្បញ្ញត្តិដែលចែងថា អង្គបុរេជំនុំជម្រះ អាចធ្វើការប្រកាសមោឃភាពនៃកិច្ចស៊ើបសួរ តាមគំនិតផ្តួចផ្តើមរបស់ខ្លួនឡើយ ។ ដូច្នេះ អង្គបុរេជំនុំជម្រះ មានសមត្ថកិច្ចតែលើពាក្យសុំរបស់ភាគី ដែលបានដាក់ជូនប៉ុណ្ណោះ ។ សាលដីកាលើពាក្យសុំមោឃភាពរបស់ នួន ជា, កំណត់សម្គាល់ទី២៤ *ខាងលើ,* កថាខណ្ឌទី២៣, ៣៤, ៣៥ ។

[26] វិធាន ៧៦.២ នៃវិធានផ្ទៃក្នុង ។ សូមមើលផងដែរ, *ដូចមុនដដែល* ។

[27] ពាក្យសុំ, កំណត់សម្គាល់ទី១ *ខាងលើ,* កថាខណ្ឌទី១៦៖ "ឥឡូវនេះ ហាក់បីដូចជាមិនមានយន្តការណាមួយទំនងជាត្រូវបានបង្កើតឡើងដើម្បីស៊ើបសួរ [...] បញ្ហាស្មុគ្រស្មាញនេះ ។

00337352



របស់រាជរដ្ឋាភិបាលកម្ពុជា (វិធាន ៦.៥) ឬ ទី ២) យុត្តាធិការព្រហ្មទណ្ឌធម្មតានៃសាលាដំបូងរាជធានីភ្នំពេញ ។

១៨. នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានកំពុងចរចា ដើម្បីដោះស្រាយនូវដំណើរការនីតិវិធីខាងវិន័យមួយដ៏មានអត្ថន័យ មេធាវីបរទេសការពារក្តីជនត្រូវចោទឈ្មោះ នួន ជា បានផ្តួចផ្តើមឡើងនូវដំណើរការនីតិវិធីព្រហ្មទណ្ឌមួយ នៅចំពោះមុខសាលាដំបូងរាជធានីភ្នំពេញ។ សកម្មភាពទាំងពីរនេះ កំពុងបន្តដំណើរការទៅមុខទៀត ។ បន្ថែមលើនេះ សូម្បីតែមានអង្គហេតុពិតដែលថា បច្ចុប្បន្ននេះដំណោះស្រាយនានាពីខាងក្រៅនៅមិនទាន់បាន លេចចេញជាលទ្ធផលដែលចង់បាននៅឡើយក៏ដោយ ហើយសូម្បីតែការសន្មតថាមានគោល បំណងទាំងឡាយនាពេលនេះដែលថាមានដំណោះស្រាយនានាពីខាងក្រៅ ក៏ត្រូវបានប្រើអស់ លទ្ធភាពរួចទៅហើយដែរនោះ[28] ពាក្យសុំនេះគឺនៅតែមិនទាន់បានចង្អុលទៅថាតើរដ្ឋអំណាចណាមួយ ដែលអាចនឹងគាំទ្រដល់អំណាចនៃតុលាការនេះ ដើម្បីទទួលយកនូវសកម្មភាពដែលបានស្នើនេះ ដែលមិនមានវត្តមាននៃប្រសិទ្ធភាពទៅលើសិទ្ធិក្នុងការទទួលបាន នូវការកាត់សេចក្តីមួយដោយយុត្តិធម៌នោះ[29] ។

### *របាយការណ៍របស់ OIOS អាចនឹងផ្សព្វផ្សាយដើម្បីភាពជឿជាក់របស់តុលាការនេះ*

១៩. ទោះបីមិនមានយុត្តាធិការក៏ដោយ ក៏នៅមានមូលហេតុផ្សេងៗតម្រូវឱ្យមានការលើកឡើងអំពីតម្លាភាព និងអំណាចរបស់តុលាការនេះ។ បញ្ហាដែលលើកឡើងអំពីអំពើពុករលួយនេះ គឺបានធ្វើឱ្យមានការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់អង្គជំនុំជម្រះនេះ ដោយមិនអាចប្រកែកបាន។

---

[28] *ដូចមុនដដែល*, កថាខណ្ឌទី១៧-១៨ ។

[29] សូមមើល *រដ្ឋអាជ្ញា ទល់នឹង Joseph Nzirorera*, សំណុំរឿងលេខ ICTR-44-T, សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទសុំផ្លាស់ប្តូរមេធាវីការពារក្តីដែលបានចាត់តាំង, អង្គជំនុំជម្រះសាលាដំបូងទីII, ថ្ងៃទី០៣ តុលា ២០០១, កថាខណ្ឌទី២០ ។ អង្គជំនុំជម្រះសាលាដំបូង ទទួលស្គាល់ថាការចោទប្រកាន់អំពីការបែងចែកប្រាក់កំរៃ(fee-splitting) គឺជា"ការចោទប្រកាន់ដ៏ធ្ងន់ធ្ងរមួយ ដែលចាំបាច់ត្រូវតែធ្វើការស៊ើបអង្កេត ដោយអាជ្ញាធរមានសមត្ថកិច្ចសមស្រប" (កថាខណ្ឌទី២០) ។ ទោះជាយ៉ាងនេះក៏ដោយ អង្គជំនុំជម្រះសាលាដំបូងនេះ យល់ឃើញថាការចោទប្រកាន់អំពីភាពមិនស្មោះត្រង់ពីរឿងប្រាក់កាសរបស់ក្រុមមេធាវីការពារក្តី គឺជាបញ្ហាផ្នែករដ្ឋបាល ដែលស្ថិតនៅក្រោមអំណាចរបស់ការិយាល័យក្រឡាបញ្ជី (Registry) តែមិនមែនស្ថិតនៅក្រោមអំណាចរបស់អង្គជំនុំជម្រះសាលាដំបូងទេ ។

២០. ជាទីបញ្ចប់ សហព្រះរាជអាជ្ញាសង្កេតឃើញថា ភាពជឿជាក់នៃដំណើរការរបស់តុលាការនេះ នឹងត្រូវបានជួយលើកតម្កើងតាមរយៈការបញ្ចេញរបាយការណ៍របស់ OIOS និងតាមរយៈការដោះស្រាយបញ្ហានេះប្រកបដោយការជឿទុកចិត្ត និងទាន់ពេលវេលា។

## ៣. សំណើ

២១. ជាសេចក្តីសរុប សហព្រះរាជអាជ្ញា សូមធ្វើសេចក្តីសន្និដ្ឋានសម្រាប់ជាការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង ដូចតទៅ ៖

i) អង្គជំនុំជម្រះសាលាដំបូង ត្រូវពន្យារពេលធ្វើសេចក្តីសម្រេចលើពាក្យសុំរហូតដល់ពេលដែលអង្គបុរេជំនុំជម្រះ បានសម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងបួន ស្តីពីខ្លឹមសារនៃអំពើពុករលួយ នៅចំពោះមុខខ្លួនសិន ។

ii) បើ អង្គជំនុំជម្រះសាលាដំបូង ជ្រើសរើសសម្រេចអំពីបញ្ហានេះនៅមុនការសម្រេចរបស់អង្គបុរេជំនុំជម្រះនោះ អង្គជំនុំជម្រះសាលាដំបូង គួរបដិសេធចោលនូវពាក្យសុំទាំងនោះ ។

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៩

សហព្រះរាជអាជ្ញា

CO-PROSECUTEURS CO-PROSECUTORS C.C.C * C.E.T.C

លោកស្រី ជា លាង          លោក Robert PETIT